**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ និងការបែងចែកតំបន់គ្រប់គ្រងដែនជម្រកសត្វព្រៃពាមក្រសោប ខេត្តកោះកុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១:-**

ត្រូវបានកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ដែនជម្រកសត្វព្រៃពាមក្រសោប លើផ្ទៃដីសរុបទំហំ ២៥ ៨៩៧ ហិកតា ដូចមានផែនទី និងនិយាមកាភ្ជាប់ជាមួយ។

**មាត្រា២:-**

ត្រូវបានបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ដែនជម្រកសត្វព្រៃពាមក្រសោប ខេត្តកោះកុង ជា ៤ តំបន់ រួមមានៈតំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ សម្រាប់បម្រើដល់ការងារគ្រប់គ្រង ថែរក្សា អភិរក្ស និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព។

www.pheakdeylaw.com

១ - តំបន់ស្នូល មានទំហំសរុប ១ ៥៨៨ ហិកតា ស្ថិតនៅក្នុងភូមិ២ នៃឃុំកោះកាពិ ភូមិកោះអណ្តែត ឃុំតាតៃ ស្រុកកោះកុង ភូមិ១ ភូមិ២ នៃឃុំពាមក្រសោប និងភូមិទួលគគីរលើ ឃុំទួលគគីរ ស្រុកមណ្ឌលសីម៉ា ខេត្តកោះកុង ដែលមាននិយាមកា ក្នុងតារាងឧបសម្ព័ន្ធ ១ និងផែនទីឧបសម្ព័ន្ធ ៥។

២ - តំបន់អភិរក្ស មានទំហំសរុប ៤ ៨៧៣ ហិកតា ស្ថិតនៅក្នុងភូមិ១ ភូមិ២ នៃឃុំពាមក្រសោប ភូមិតាចាត ភូមិទួលគគីរលើ នៃឃុំទួលគគីរ ស្រុកមណ្ឌលសីម៉ា ភូមិ២ នៃឃុំកោះកាពិ និងភូមិកោះអណ្តែត ភូមិអន្លង់វ៉ាក់ នៃឃុំតាតៃ ស្រុកកោះកុង ខេត្តកោះកុង ដែលមាននិយាមកាក្នុងតារាងឧបសម្ព័ន្ធ ២ និងផែនទីឧបសម្ព័ន្ធ ៥ ។

៣ - តំបន់ប្រើប្រាស់ដោយចីរភាព មានទំហំសរុប ១៥ ៤១៣ ហិកតា ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោប ដែលមាននិយាមកាក្នុងតារាងឧបសម្ព័ន្ធ ៣ និងផែនទីឧបសម្ព័ន្ធ ៥ ។

៤ - តំបន់សហគមន៍ មានទំហំសរុប ៤ ០២៣ ហិកតា ស្ថិតនៅក្នុងភូមិព្រែកស្វាយ ភូមិស្ទឹងវែង នៃសង្កាត់ស្ទឹងវែង ក្រុងខេមរៈភូមិន្ទ ភូមិ២ នៃឃុំពាមក្រសោប ភូមិតាចាត ភូមិទួលគគីរក្រោម ភូមិកោះចាក នៃឃុំទួលគគីរ ភូមិបឹងកាឆាង នៃឃុំប៉ាកខ្លង ស្រុកមណ្ឌលសីម៉ា ភូមិ១ ភូមិ២ ភូមិកោះស្រឡៅ នៃឃុំកោះកាពិ និងភូមិកោះអណ្តែត នៃឃុំតាតៃ ស្ថិតក្នុងស្រុកកោះកុង ខេត្តកោះកុង ដែលមាននិយាមកាក្នុងតារាងឧបសម្ព័ន្ធ៤ និងផែនទីឧបសម្ព័ន្ធ៥ ។

**មាត្រា៣:-**

ការកំណត់និងការបែងចែកតំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃពាមក្រសោប នឹងមានការកែប្រែក្នុងករណីចាំបាច់តាមការសិក្សាស្រាវជ្រាវភូមិសាស្ត្រជាក់ស្តែង លើគម្រោងអភិរក្សជីវៈចម្រុះ ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។ គោលការណ៍នៃការគ្រប់គ្រងតំបន់នីមួយៗត្រូវអនុវត្តស្របទៅតាមច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ។

**មាត្រា៤:-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

PheakdeyLaw Book Store

**មាត្រា៥:-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ៧ ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

www.pheakdeylaw.com